00159042

C22/I/5

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ០៣)

បញ្ជូនទៅ: អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨

ភាគីបញ្ជូន: សហមេធាវីការពារលោក អៀង សារី

ភាសាដើម: សំណៅដើមជាអង់គ្លេស

ប្រភេទឯកសារ: សាធារណៈ

---

## សារណារបស់លោក អៀង សារី ដើម្បីគាំទ្រដល់ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន

---

**បញ្ជូនដោយ៖**

សហមេធាវីការពារលោក អៀង សារី

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**ចែកចាយជូន៖**

**អង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន៍យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification):
15 / 01 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
15 / 01 / 2008
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA KOSAL

## I. សេចក្ដីផ្ដើម

1. អនុលោមទៅតាមវិធាន ៦៣(៤) និង ៧៤(៣) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅថា"វិធានផ្ទៃក្នុង") លោក អៀង សារី តាមរយៈមេធាវីការពារក្ដីរបស់ខ្លួន សុំដាក់សារណា ដើម្បីគាំទ្រដល់បណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅលើដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន (ហៅថា"ដីកាសម្រេចឃុំខ្លួន") ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា" ក.ស.ច.ស.") នៅថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ដែលបង្គាប់ឱ្យឃុំខ្លួនលោក អៀង សារី បណ្ដោះអាសន្នចំនួនរយៈពេលអតិបរមា ១ ឆ្នាំ[1]។

2. ជាពិសេស ក.ស.ច.ស. បានសម្រេចថាការឃុំខ្លួនបណ្ដោះអាសន្នគឺចាំបាច់ ដោយសារតែ ក) មានឯកសារជាច្រើនគាំទ្រដល់"មូលហេតុជាក់លាក់ដែលជឿថាលោក អៀង សារី បានចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ[2] ខ) ដើម្បីបង្កាហានិភ័យដល់សណ្ដាប់ធ្នាប់សារណៈ[3] គ) គាត់អាចធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរបស់គាត់[4] និង សន្តិសុខអ្នកដទៃ[5] ឃ) មានហានិភ័យថាគាត់រត់គេច[6] ង) មិនមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដើម្បីលុបបំបាត់ហានិភ័យនៃការរត់គេច ឬ ភាពគ្រោះថ្នាក់ដល់ខ្លួនឯង ឬ អ្នកដទៃនោះទេ[7] និង ច) អាស្រ័យលើកំណត់ត្រាផ្នែកវេជ្ជសាស្ត្រដែលមានបង្ហាញថាស្ថានភាពសុខភាពរបស់លោក អៀង សារី មិនមែនមិនសមនឹងការឃុំខ្លួននោះឡើយ"[8] ។

3. បន្ថែមពីលើការថ្លែងហេតុផលសម្រាប់ឱ្យពួកគេជឿថាការឃុំខ្លួនគឺចាំបាច់ សហចៅក្រមស៊ើបអង្កេតបានពិភាក្សានៅក្នុងដីកាសម្រេចឃុំខ្លួន លើបញ្ហាពីរបន្ថែមទៀតដែលមិនមែនជាកម្មវត្ថុផ្ទាល់របស់សវនាការតទល់គ្នា ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ នោះគឺ ៖ ក)"*ne bis in*

---

1 ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ០០២/១៩.០៩.២០០៧/អ.វ.ត.ក/ក.ស.ច.ស. ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ទំព័រ ៧

2 ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន នៅកថាខណ្ឌ ១៥

3 ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន នៅកថាខណ្ឌ ១៦

4 ដូចខាងលើ

5 ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន នៅកថាខណ្ឌ ១៧

6 ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន នៅកថាខណ្ឌ ១៨

7 ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន នៅកថាខណ្ឌ ១៩

8 ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន នៅកថាខណ្ឌ ២០

*idem*[9] ជនម្នាក់មិនអាចត្រូវបានចោទប្រកាន់ ឬ ផ្តន្ទាទោសចំពោះបទល្មើសដែលត្រូវបានសម្រេចថាគ្មានទោស ឬ ផ្តន្ទាទោសរួចហើយនោះទេ” និង ខ) វិសាលភាពនៃព្រះរាជក្រឹត្យឆ្នាំ ១៩៩៦ ដែលលើកលែងទោស និង អនុគ្រោះទោសដល់លោក **អៀង សារី**[10] ។ មុនសវនាការតទល់គ្នា មេធាវីរបស់លោក **អៀង សារី** ពុំត្រូវបានជូនដំណឹងជាមុនឡើយ ហើយជាផលវិបាក សហមេធាវីពុំបានទទួលការណែនាំឱ្យរាយរាប់ពីបញ្ហាទាំងនេះ មុនការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

## II. ទស្សនៈសង្ខេប

4. ដើម្បីពិនិត្យពាក្យបណ្តឹងឧទ្ធរណ៍ គេគប្បីពិចារណាលើសំណួរសំខាន់ចំនួនបួន(៤)។ ទីមួយ តើការឃុំខ្លួនបណ្តោះអាសន្ន **អៀង សារី** គឺជាការចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈឬទេ? ទីពីរ តើការឃុំខ្លួនបណ្តោះអាសន្នលោក អៀង សារី គឺជាការចាំបាច់ដើម្បីរក្សាសន្តិសុខរបស់គាត់ឬទេ? ទីបី តើការឃុំខ្លួនបណ្តោះអាសន្នលោក អៀង សារី គឺជាការចាំបាច់ដើម្បីទប់ស្កាត់គាត់មិនឱ្យរត់គេចឬទេ? និងទីបួន តើការឃុំខ្លួនបណ្តោះអាសន្នលោក **អៀង សារី** គឺជាការចាំបាច់ ដោយសារតែពុំមានវិធានការត្រួតពិនិត្យតាមផ្លូវតុលាការណាមួយ ដើម្បីលុបបំបាត់ភាពគ្រោះថ្នាក់ដល់ខ្លួនគាត់ ឬ ដល់អ្នកដទៃ និង ហានិភ័យនៃការរត់គេចឬទេ?

5. ប្រសិនបើគ្មានការលើកឡើងពីការយល់ឃើញរបស់ ក.ស.ច.ស. នៅក្រោមវិធាន ៦៣(៣)(ក) ថាមានមូលហេតុជាក់លាក់ដើម្បីជឿថាលោក **អៀង សារី** ប្រហែលបានចូលរួមឧក្រិដ្ឋកម្មដែលមានកំណត់នៅក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ សារណាបណ្តឹងឧទ្ធរណ៍នេះ យ៉ាងណាក៏ដោយនឹងបង្ហាញឱ្យឃើញថា ក.ស.ច.ស. មានការភ័ន្តច្រឡំក្នុងការអនុវត្តយុត្តាធិការរបស់ខ្លួន តាមការយល់ឃើញរបស់ខ្លួនក្រោមវិធាន ៦៣(៣)(ខ)។ បន្ថែមពីលើនេះ ដោយគិតដល់ការយល់ឃើញរបស់ ក.ស.ច.ស. ទាក់ទងនឹងលក្ខខណ្ឌសុខភាពរបស់លោក **អៀង សារី** មានការផ្តល់ឯកសារវេជ្ជសាស្ត្របន្តបន្ទាប់ ដែលមានហេតុផលគួរឱ្យជឿថា ក្រោមលក្ខខណ្ឌនិងទីកន្លែងឃុំខ្លួនបច្ចុប្បន្ន សុខភាពរបស់លោក **អៀង សារី** ស្ថិតនៅក្នុងស្ថានភាពហានិភ័យពិតៗ ហើយជាផលវិបាក គួរឱ្យមានបរិយាកាសឃុំខ្លួនមួយដែលមានលក្ខណៈធូរស្រាលក្នុងកម្រិតអប្បបរមា។

6. លោក **អៀង សារី** នឹងមិនលើកឡើង - ជាផ្នែកមួយនៃសារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងលើដីកាឃុំខ្លួនបណ្តោះអាសន្ន - នូវរាល់បញ្ហាដែលទាក់ទងនឹង *ne bis in idem* “គ្មានការកាត់ទោសពីរដងចំពោះ

---

9 ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន នៅកថាខណ្ឌ ៥-១០

10 ដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន នៅកថាខណ្ឌ ៥-៦, ១១-១៤,

បទល្មើសតែមួយ" និង ព្រះរាជក្រិត្យលើកលែងទោស និង អនុគ្រោះទោសដល់លោក **អៀង សារី** នៅពេលនេះ ប៉ុន្តែសុំរក្សាសិទ្ធិដើម្បីធ្វើការជំទាស់នឹង ក.ស.ច.ស. លើការវិភាគផ្នែកច្បាប់ និង ការយល់ឃើញណាទាំងអស់ចំពោះបញ្ហាទាំងនេះ នៅពេលវេលាសមស្របណាមួយ។ សេចក្តីសម្រេចរបស់លោក **អៀង សារី** ក្នុងការមិនលើកពីបញ្ហា *ne bis in idem* "គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ" និង ព្រះរាជក្រិត្យលើកលែងទោស និង អនុគ្រោះទោស នៅពេលនេះ មិនត្រូវយល់ថាជាការលះបង់សិទ្ធិចោលនៅពេលក្រោយឡើយ។

## III. ឧទ្ធិករណ៍

### *ក. ពុំមានហានិភ័យជាក់លាក់ដល់សណ្តាប់ធ្នាប់សាធារណៈ*

7. ពុំមានភស្តុតាងគួរឱ្យជឿទុកចិត្ត ដើម្បីសន្និដ្ឋានថា ការដោះលែងលោក **អៀង សារី** ឱ្យនៅក្រៅឃុំបណ្តោះអាសន្នរង់ចាំសវនាការ នឹងប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈនោះទេ។ សហចៅក្រមស៊ើបអង្កេតបានលើកឡើងដោយគ្មានភស្តុតាងច្បាស់លាស់ ហើយគ្រាន់តែស្មានៗថា ៖

> "អង្គហេតុនេះមានលក្ខណៈធ្ងន់ធ្ងរ ទោះជាវាមានរយៈពេល ៣០ ឆ្នាំ ក្រោយពេលបទឧក្រិដ្ឋបានកើតឡើងក៏ដោយ ក៏នៅតែបង្កជាបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល។ ហេតុដូច្នេះវាមិនមែនជាការហួសហេតុពេកទេ ដែលអះអាងថានៅក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឱ្យមានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឱ្យមានអំពើហឹង្សា ឬ អាចប៉ះពាល់ដល់សន្តិសុខរបស់ជនត្រូវចោទផ្ទាល់។ ម្យ៉ាងវិញទៀត ស្ថានភាពមិនអាចមើលឃើញជាក់ច្បាស់ដូចគ្នាទេ រវាងពេលមុនការចោទប្រកាន់ និង ក្រោយពេលចោទប្រកាន់ជាផ្លូវការនោះ" ។

8. សហចៅក្រមស៊ើបអង្កេតពុំបានចង្អុលបង្ហាញថា អ្វីខ្លះដែលបង្កើតបាន"ជាបរិបទផុយស្រួយ"។ ប្រសិនបើចំណុចនោះមានន័យថា សង្គមកម្ពុជាបច្ចុប្បន្ននៅតែជារដ្ឋក្រោយពេលជម្លោះ ហើយជាផលវិបាក ការដោះលែងឱ្យនៅក្រៅឃុំណាមួយអាចបង្កមានមហាបាតុកម្មតវ៉ានិងអំពីហិង្សា ដូច្នេះសំនួរដែលសុំឱ្យមានចម្លើយគឺថា ចុះហេតុអ្វីបានជានៅតំបន់ក្រោយជម្លោះដទៃៗទៀត ដែលសង្គមទាំងនោះពិតជាផុយស្រួយមែន ហើយតុលាការអន្តរជាតិនៅតែបានដោះលែងជនជាប់ចោទឱ្យនៅក្រៅឃុំបណ្តោះអាសន្ននៅមុន និង អំឡុងពេលសវនាការ ទោះបីបទឧក្រិដ្ឋដែលចោទប្រកាន់ទាំងនោះធ្ងន់ធ្ងរ ឬ ជនជាប់ចោទទាំងនោះធ្លាប់កាន់មុខតំណែងខ្ពស់យ៉ាងណាក្តី។

9. ប្រសិនបើសង្គមកម្ពុជាបច្ចុប្បន្នផុយស្រួយ ដូចសហចៅក្រមបានអះអាងមែន នោះការជំនុំជម្រះក្តីត្រូវតែកំណត់ថាមានពិរុទ្ធ ហើយសាលក្រមត្រូវតែផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត - ដោយមិនចាំបាច់គិតពីភស្តុតាងផ្ទុយ - បើមិនដូច្នេះទេ អាចនឹងបង្កឲ្យមានការតវ៉ាពីអ្នកមិនពេញចិត្តដែលអាចនាំឲ្យមានអំពើហិង្សា។ សញ្ញាណនេះឯង ប្រសិនបើជារឿងពិត ជាក់ស្តែង នឹងបង្កឲ្យមានបញ្ហាចោទ ហើយបង្កឲ្យមានមន្ទិលសង្ស័យថា ជនសង្ស័យណាក្តីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញនេះអាចរំពឹងប្រាកដថាទទួលបានការជម្រះក្តីប្រកបដោយយុត្តិធម៌ និង ឥតលំអៀងដែរឬទេ បើពិចារណាពីសំពាធលើចៅក្រម ដើម្បីបញ្ចៀសការមិនពេញចិត្ត និង អំពីហិង្សាដែលអាចបង្កពីការប្រកាស សាលក្រម ដែលមិនផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគារអស់មួយជីវិត។

10. ដោយមិនយល់ស្របថា សង្គមកម្ពុជាបច្ចុប្បន្នផុយស្រួយ ជាការប្រពៃណាស់ដែលធ្វើឲ្យទឹកឃើញថាគ្មានការតវ៉ាពីការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហឹង្សា ដោយប្រៀបធៀបទៅនឹងបរិបទដ៏ផុយស្រួយនៃសង្គមកម្ពុជានាអតីតកាល នៅពេល **អៀង សារី** វិលត្រឡប់ចូលសង្គមជាតិវិញ បន្ទាប់ពីមានការប្រកាសព្រះរាជក្រិត្យលើកលែង និង អនុគ្រោះទោសឲ្យគាត់។

11. អនុលោមតាមនិយាមអន្តរជាតិ ការធ្វើយុត្តិកម្មផ្នែកសណ្តាប់ធ្នាប់សាធារណៈអាចត្រូវបានប្រើប្រាស់តែនៅពេលណាមានអង្គហេតុបង្ហាញថា ការដោះលែងជនជាប់ចោទអាចប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈពិតៗ ហើយការឃុំខ្លួនជាមធ្យោបាយតែមួយគត់ដើម្បីបញ្ចៀសការប៉ះពាល់ដល់សណ្តាប់ធ្នាប់ជាក់ស្តែង[11] ។

12. ពុំមានភស្តុតាងដែលអាចជឿទុកបាន ដើម្បីគាំទ្រដល់ការអះអាងណាមួយដែលថា សង្គមកម្ពុជាស្ថិតនៅក្នុងស្ថានភាពផុយស្រួយ ហើយត្រូវទទួលខុសត្រូវក្នុងការបំបែកការតវ៉ាដែលហឹង្សាឡើយ។ ការិយាល័យសហព្រះរាជអាជ្ញា (“ក.ស.ព.”) បានលើកឡើងជាភស្តុតាងអំពើពុករលួយប្រឆាំងនឹងថៃកាលពីឆ្នាំ ២០០៣ ថាកម្ពុជាជាសង្គមមួយគ្មានស្ថិរភាពនោះ គឺមិនអាចជឿបានទេ[12]។ មានឧទាហរណ៍ដោយឡែកៗផ្សេងទៀតនៃការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ដែលមិនចាំបាច់គិតថាវាធ្វើឲ្យសង្គមមួយ“ផុយស្រួយ” ឬ គ្មានស្ថិរភាពបានឡើយ។

13. មានប្រទេសជាច្រើនដែលទទួលរងនូវការប៉ះពាល់ដល់សណ្តាប់ធ្នាប់សារធារណៈ។ ឧទាហរណ៍ ក្នុងអំឡុងពេល ៥ ឆ្នាំកន្លងមកនេះ អតីតម្ចាស់អំណាចអាណានិគមន៍លើកម្ពុជាគឺប្រទេសបារាំង មាន

---

11 *ករណី Letellier តទល់ជាមួយសាធារណៈបារាំង* ECHR ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ១៩៩១

12 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ចុះនៅថ្ងៃទី ១៩ ខែកញ្ញា ២០០៧, ថ្ងៃទី៣ ខែធ្នូ ២០០៧ កថាខណ្ឌ ៣៨ ។

អំពើរំខានដល់សណ្ដាប់ធ្នាប់សាធារណៈក្នុងទ្រង់ទ្រាយធំកាលពីឆ្នាំ ២០០៣ ឆ្នាំ ២០០៥ និងម្ដងទៀត នៅឆ្នាំ ២០០៧។ នៅជិតខាងកម្ពុជាគឺប្រទេសថៃ មានកើតមហាបាតុកម្មជាច្រើនសប្ដាហ៍នៅឆ្នាំ ២០០៦ បន្ទាប់ពីពួកយោធាបានធ្វើរដ្ឋប្រហារផ្ដួលរំលំរដ្ឋាភិបាលដែលជ្រើសរើសតាមបែបប្រជាធិបតេយ្យ។ នាពេលថ្មីនេះ មានការផ្ទុះឡើងនូវអំពើកុប្បកម្មនៅប្រទេសអ៊ីតាលី ដែលបង្កឡើងពីការប្រកួតបាល់ទាត់។ អំពើបាតុកម្មដែលបំផុសកំហឹងឡើងដោយជាតិសាសន៍ តែងកើតមានឡើងនៅសហរដ្ឋអាមេរិក និង ចក្រភពអង់គ្លេស។ ជាការពិតណាស់ ការរំខានដល់សណ្ដាប់ធ្នាប់សាធារណៈជាទៀងទាត់ពេលកើតឡើងនៅសាធារណៈរដ្ឋនានា និង នៅតំបន់ស្វ័យតជាច្រើន នៅអតីតយូហ្គោស្លាវី (សែប៊ី ក្រូអាត បូស្នៀ និង ហែហ្សេហ្គោវីណា និង កូសូវ៉ូ) ដោយសារតែភាពអយុត្តិធម៌ដែលបង្កឡើងពីការជំនុំជម្រះក្ដី ដែលកំពុងតែប្រព្រឹត្តិទៅនៅតុលាការអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី ("ICTY")។ ប្រៀបធៀបទៅនឹងឧទាហរណ៍ទាំងនេះ ប្រទេសកម្ពុជាមានរូបភាពពេញដោយសន្តិភាព និង ស្ថិរភាព។

14. ទោះបីនៅក្នុងសង្គមដែលពិតជាផុយស្រួយ តុលាការអន្តរជាតិបានដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នដល់ជនដែលត្រូវចោទពីបទរំលោភបំពានច្បាប់មនុស្សធម៌។ ឧទាហរណ៍ នៅកូសូវ៉ូ មានការកើតឡើងនូវ"រលកកុប្បកម្មទូទាំងខេត្តមួយនេះ" កាលពីខែមិនា ឆ្នាំ ២០០៤ ដែលជាប់ពាក់ព័ន្ធនឹងមនុស្ស ៥១.០០០ នាក់[13]។ មានលំនៅដ្ឋាន ៧៣០ ខ្នងរបស់ជនជាតិភាគតិច ត្រូវប៉ាន់ប្រមាណថាបានបំផ្លិចបំផ្លាញ ហើយមានជនជាតិ កូសូវ៉ូ សែប៊ី ប្រមាណ ៤.០០០ នាក់ត្រូវបានផ្លាស់ទីជម្រក[14]។ ថ្វីបើមាន អំពើហិង្សាទាក់ទងនឹងជាតិពន្ធុនៅឆ្នាំ ២០០៥ យ៉ាងណាក្ដី ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតយូហ្គោស្លាវី (ICTY) នៅបានដោះលែង Ramush Haradinaj ជាអតីតមេដឹកនាំកងទ័ពរំដោះ កូសូវ៉ូ ឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន ទោះបីគាត់ប្រឈមនឹងការចោទប្រកាន់ពាក់ព័ន្ធនឹងជម្លោះជាតិពន្ធុ កូសូវ៉ូ សែប ជាមួយនឹង អាល់បែនី[15] ក្ដី។

---

13 សូមមើល OSCE "Kosovo ការឆ្លើយតបរបស់ប្រព័ន្ធយុត្តិធម៌ទៅនឹងអំពើកុប្បកម្ម ខែមិនា ឆ្នាំ ២០០៤" ខែធ្នូ ឆ្នាំ ២០០៥ ទំព័រ ៥ ដល់ ៦ ។

14 ចំពោះទិន្នន័យទាក់ទងនឹងកុប្បកម្មខែមិនា ឆ្នាំ២០០៤ និង វិធានការបន្តបន្ទាប់ សូមមើលគេហទំព័រ http://www.ian.org.yu/kosovo-info/english/files-index/Fact%20SheetMeasures%20after%20March%20updated%20March%202005.pdf

15 *សូមមើលករណីព្រះរាជអាជ្ញា តទល់ជាមួយ Haradinaj et al.,..* IT-04-84-PT សេចក្ដីសម្រេចស្ដីពីពាក្យសុំដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នរបស់ Haradinaj ចុះនៅថ្ងៃទី ៦ ខែមិថុនា ២០០៥ ។

00159048



15. ដូចគ្នាដែរ សហចៅក្រមស៊ើបអង្កេតមិនបានផ្តល់មូលដ្ឋានអង្គហេតុលើការយល់ឃើញរបស់ខ្លួន ដែលថាការដោះលែងលោក អៀង សារី អាចបង្កឱ្យមានការប្រឆាំងតវ៉ាពីសាធារណៈជន និង មានអំពើហិង្សា។ វានៅតែជាអាថ៌កំបាំងដដែល ដែលសហចៅក្រមស៊ើបអង្កេតកំណត់ថាឧក្រិដ្ឋកម្មនានាដែលត្រូវបានលើកឡើង "នៅតែបង្កជាបញ្ហាដល់សណ្តាប់ធ្នាប់សាធារណៈ"។ សហចៅក្រមស៊ើបអង្កេតមិនបានទាញយករបាយការណ៍ណាមួយ ដែលទាក់ទងនឹងអស្ថិរភាពមកអះអាងឡើយ ហើយក៏មិនបានយោងទៅលើឧប្បត្តិហេតុណាមួយនៃការតវ៉ាពីសាធារណៈជនដែលទាក់ទិននឹងខ្មែរក្រហមទេ។ ទោះបីជាមានអតីតមេដឹកនាំខ្មែរក្រហមមួយចំនួនដែលត្រូវបានចោទប្រកាន់ រួមទាំងលោក អៀង សារី ផង ធ្លាប់បានរស់នៅយ៉ាងសេរីនិងដោយចំហ នៅទីក្រុងភ្នំពេញជាច្រើនឆ្នាំហើយក្តី ក៏សហចៅក្រមស៊ើបអង្កេតមិនបានលើកឡើងនូវឧទាហរណ៍ណាមួយ ស្តីពីការតវ៉ារបស់សាធារណៈជន ចំពោះសេរីភាពរបស់ពួកគេក្នុងការធ្វើដំណើរ នៅក្នុងនិងក្រៅប្រទេសកម្ពុជាដែរ។

16. សូមជម្រាបអង្គបុរេជំនុំជម្រះដោយក្តីគោរពថា រូបភាពនៃសង្គមកម្ពុជា គឺខុសគ្នាខ្លាំងណាស់ពីអ្វីដែលត្រូវបានលាបពណ៌ដោយ ក.ស.ព. និង សហចៅក្រមស៊ើបអង្កេត។ ប្រភពរបស់រដ្ឋាភិបាលព្រមទាំងភ្នាក់ងារអន្តរជាតិឯករាជ្យនានា ទទួលស្គាល់ថាកម្ពុជាបច្ចុប្បន្នគឺជាប្រទេសមានសន្តិភាព និង ស្ថិរភាព។ ឧទាហរណ៍ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលបានមានប្រសាសន៍នាពេលថ្មីៗនេះថា៖

"ប្រទេសកម្ពុជាបានឆ្លងកាត់ដំណាក់កាលផ្លាស់ប្តូរទាំងស្រុង មិនត្រឹមផ្នែកនយោបាយ និងសន្តិសុខប៉ុណ្ណោះទេ ក៏ប៉ុន្តែព្រមទាំងផ្នែកសេដ្ឋកិច្ច និង ទិដ្ឋភាពសង្គមផងដែរ។ បរិយាកាសស្ថិរភាព សុវត្ថិភាព និង សន្តិសុខនេះ ជាលក្ខខណ្ឌបុរេដ៏សំខាន់មួយសំរាប់កម្ពុជាដែលធ្វើឱ្យបានសម្រេចនូវសក្តានុពលផ្នែកសេដ្ឋកិច្ច និង សង្គមរបស់ខ្លួន នៅក្នុងប្រជាជាតិមួយដែលមានសន្តិសុខ និង វិបុលភាព[16]" ។ (បញ្ជាក់បន្ថែម) ។

17. តាមរបាយការណ៍ថ្មីៗមួយរបស់ក្រសួងផែនការ និង UNDP បានអះអាងថា ៖

"កម្ពុជាសម្រេចបានកត់ត្រានូវសមិទ្ធិផលនានាគួរឱ្យចាប់អារម្មណ៍ខ្លាំង ជាពិសេសដោយគិតទៅដល់ជម្លោះប្រណាំងប្រជែងខ្លះនៅទសវត្សមុនៗ។ <u>សំខាន់បំផុតនោះគឺ</u> សន្តិភាព និង ស្ថិរភាព ដែលត្រូវបានស្ថាបនាឡើងវិញយ៉ាងធំធេង ដោយហេតុនោះហើយ ទើបមានការកើនឡើងនូវសន្តិសុខរបស់មនុស្ស។ ដោយភ្ជាប់ជាមួយកំណើននៅតំបន់និងលើពិភពលោក

---

[16] សន្ទរកថានៅថ្ងៃទី ២២ ខែកុម្ភះ ឆ្នាំ២០០៧ នៅវេទិការសេដ្ឋកិច្ចកម្ពុជាៈ កាលានុភាពដើម្បីរីកចំរើន វឌ្ឍនភាព និង ការចែករំលែកវិបុលភាព ។

ទាំងនេះបានជំរុញឱ្យមានស្ថិរភាព ដើម្បីកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលដប់ឆ្នាំកន្លងទៅនេះ[17]។ (បញ្ជាក់បន្ថែម)

18. ទស្សនៈយល់ឃើញខាងលើគឺស៊ីសង្វាក់គ្នាជាមួយធនាគារពិភពលោក ដែលបញ្ជាក់ថា ៖

“រយៈពេលមួយទសវត្សកន្លះកន្លងមកនេះ ប្រទេសកម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចក្នុងអត្រាខ្ពស់ និង ការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សំគាល់ ... [កិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ ១៩៩១] បានកត់សំគាល់ពីការចាប់ផ្ដើមដំណាក់កាលអន្តរកាល ពីសង្គ្រាមមកសន្តិភាព ដោយការនាំភាគីជម្លោះក្នុងសង្គ្រាមស៊ីវិលស្ទើរតែទាំងអស់នៃទសវត្ស ១៩៨០ ឱ្យចូលមកក្នុងកិច្ចព្រមព្រៀង ដើម្បីប្រកួតប្រជែងដណ្តើមអំណាចតាមរយៈការបោះឆ្នោតជាជាងតាមការតស៊ូតាមផ្លូវយោធា (បើទោះបីសន្តិភាពពេញលេញទើបតែទទួលបាននៅក្នុងឆ្នាំ ១៩៩៩ ដោយការដួលរលំជាស្ថាពរនូវចលនាឧទ្ទាមខ្មែរក្រហមក៏ដោយ)”[18] (បញ្ជាក់បន្ថែម)។

19. ហើយយោបល់របស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ (USAID) ថា ៖

“បច្ចុប្បន្ន កម្ពុជាជាប្រទេសដែលស្ថិតក្នុងអន្តរកាលនៅកំរិតជាច្រើន។ ជាលក្ខណៈនយោបាយ ប្រទេសកម្ពុជាបានផ្លាស់ប្តូរពីកុម្មុយនិស្តឆ្ពោះទៅលទ្ធិប្រជាធិបតេយ្យ។ ជាលក្ខណៈសេដ្ឋកិច្ច កម្ពុជាបានធ្វើដំណើរពីសេដ្ឋកិច្ចមួយដែលស្ទើរតែបិទទាំងស្រុងពីពិភពលោក ទៅកាន់សេដ្ឋកិច្ចមួយដែលស្ទើរតែបើកចំហទាំងស្រុង។ ក្រោយពីមានជម្លោះច្រើនឆ្នាំ ពេលនេះ មានស្ថេរភាព និង សន្តិភាព។ [...] ជាងមួយទសវត្សកន្លងមកនេះ របៀបរៀបចំសង្គម នយោបាយ និង សេដ្ឋកិច្ចរបស់ប្រទេសនេះបានផ្លាស់ប្តូរយ៉ាងខ្លាំង ដែលជាការបង្កើតឱ្យមានឱកាសថ្មីៗជាច្រើន។”[19] (បញ្ជាក់បន្ថែម)។

20. គ្មានអ្វីគួរឱ្យឆ្ងល់នោះឡើយ រាជរដ្ឋាភិបាលកម្ពុជាបានទទួលជោគជ័យយ៉ាងខ្លាំងនៅក្នុងការស្តារសន្តិភាព និង ស្ថិរភាពជាងមួយទសវត្សកន្លងមកនេះ។ លើសពីនេះទៅទៀត វាផ្ទុយនឹងទស្សនៈយល់ឃើញរបស់ការិយាល័យសហព្រះរាជអាជ្ញា ហើយដែលបានយល់ស្របដោយសហចៅក្រមស៊ើបអង្កេត សង្គមកម្ពុជាមិនស្ថិតក្នុង“ភាពផុយស្រួយ”នោះទេ បទល្មើសដែលបានចោទប្រកាន់មិននៅតែ “រំខានយ៉ាងខ្លាំងដល់សណ្តាប់ធ្នាប់សាធារណៈ”នោះឡើយ ហើយការអនុញ្ញាតឱ្យមានការដោះលែង

---

17 របាយការណ៍អភិវឌ្ឍន៍មនុស្សឆ្នាំ ២០០៧៖ ពង្រីកជម្រើសដល់ប្រជាជនតាមជនបទ( NHDR) ទំព័រ ១១ ។

18 “ការចែករំលែកកំណើនសេដ្ឋកិច្ចៈ សមធម៌ និងការអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា” របាយការណ៍ដែលបានផ្សព្វផ្សាយនៅថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០០៧ នៅក្នុងសិក្ខាសាលារួមគ្នាមួយរវាងរាជរដ្ឋាភិបាល និង ធនាគារពិភពលោក ដែលបានប្រារព្ធធ្វើនៅសណ្ឋាគារអាំងទែកុងទីណង់តាល់ នៅក្នុងទីក្រុងភ្នំពេញ pp ១ និង ២។

19 សូមមើល វិបសាយ http://www.usaid.gov/kh/development_challenge.htm.

00159050



លោក អៀង សារី បណ្ដោះអាសន្ន *មិន* "បង្កឲ្យមានការតវ៉ាពីការមិនពេញចិត្តនិងអំពើហិង្សានោះទេ។ ការលើកឡើងថា សង្គមកម្ពុជាមានភាពផុយស្រួយខ្លាំង ដែលអាចនាំឲ្យមានអំពើហិង្សា ប្រសិនបើតុលាការអនុញ្ញាតឲ្យមានការដោះលែងបណ្ដោះអាសន្នដល់ជនដែលត្រូវសន្មត់ជាមុនថាគ្មានទោស គឺជាការមើលងាយដល់ភាពចាស់ទុំនៃសង្គមកម្ពុជា និង ជោគជ័យរបស់រាជរដ្ឋាភិបាលក្នុងការនាំមកនូវសន្តិភាពនិងស្ថិរភាព។

21. រួមសេចក្ដីមក សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយការសំអាងសេចក្ដីសម្រេចរបស់ខ្លួនទៅលើវិចារណញ្ញាណអរូបី និង លើទស្សនៈយល់ឃើញជាទូទៅ ដោយមិនពឹងផ្អែកទៅលើអង្គហេតុ។ ក្នុងការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យមានកំហុសខាងអង្គហេតុ និង បានរំលោភបំពានលើបទដ្ឋានយុត្តិធម៌អន្តរជាតិ។

## *ខ. គ្មានហានិភ័យពិតប្រាកដលើសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោក អៀង សារី*

22. សហចៅក្រមស៊ើបអង្កេតបានលើកឡើងថាការដោះលែង អៀង សារី "អាចនាំឲ្យមានអំពើហិង្សា ហើយប្រហែលអាចនាំឲ្យមានគ្រោះថ្នាក់ខ្លាំងដល់សុវត្ថិភាពរបស់ជនត្រូវចោទ"[20] បែបនេះគឺគ្មានមូលដ្ឋានអង្គហេតុ ឬ ភស្តុតាង ដើម្បីគាំទ្រដល់ការយល់ឃើញរបស់ខ្លួននោះឡើយ។

23. បញ្ហាសន្តិសុខរបស់លោក អៀង សារី មិនមែនជាហេតុផលត្រឹមត្រូវដើម្បីរក្សាទុករូបគាត់នៅក្នុងមន្ទីរឃុំឃាំងនោះទេ ជាពិសេស កាលណា ដូចមានរៀបរាប់ខាងក្រោមនេះ ស្ថានភាពឃុំឃាំងបច្ចុប្បន្នបានធ្វើឲ្យគ្រោះថ្នាក់យ៉ាងខ្លាំង (ប្រសិនបើមិនដល់ថ្នាក់បណ្ដាលឲ្យស្លាប់ទេនោះ) ដល់ស្ថានភាពសុខភាពផុយស្រួយរបស់លោក អៀង សារី។

24. លោក អៀង សារី បានរស់នៅដោយសេរី និង ចំហនៅកណ្ដាលទីក្រុងភ្នំពេញអស់ពេលជិតមួយទសវត្ស។ នៅទូទាំងរយៈពេលនោះ មានការដឹងទូទៅទៅហើយដែលថា លោក អៀង សារី បានជាប់ពាក់ព័ន្ធជាមួយ និង ជាផ្នែកនៃអតីតថ្នាក់ដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ហើយដែលថាគាត់បានរស់នៅក្នុងទីក្រុងភ្នំពេញ។ ទីតាំងលំនៅដ្ឋានរបស់គាត់ត្រូវបានគេស្គាល់យ៉ាងច្បាស់។ គ្មានកម្លាំងសន្តិសុខទោះប្រដាប់ដោយអាវុធ ឬ គ្មានប្រដាប់អាវុធក្ដី ត្រូវបានជួលឲ្យមើលលំនៅដ្ឋានរបស់គាត់ ឲ្យការពារសន្តិសុខដល់រូបគាត់ ឬ ឲ្យការពារសន្តិសុខដល់សមាជិកគ្រួសារដែលរស់ជាមួយរូបគាត់នោះទេ។ លោក អៀង សារី បានរស់នៅក្នុងជីវិតសាមញ្ញមួយនៅក្នុងលំនៅដ្ឋានមួយដែលគ្មានលេនដ្ឋានការពារ

---

[20] ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន កថាខ័ណ្ឌទី ១៦

គ្មានរបងបន្លាលួស និង គ្មានរបងដែលដាក់ចរន្តអគ្គីសនីឱ្យឆក់នោះទេ។ ជាការពិតណាស់ លោក **អៀង សារី** មិនដែលរងការជេរប្រមាថមើលងាយ ការគំរាមកំហែង ឬ ការវាយប្រហារម្តងណាទេ នៅក្នុងរយៈពេលជាងដប់ឆ្នាំ តាំងពីបានធ្វើសមាហរណកម្មជាមួយនឹងរាជរដ្ឋាភិបាលនោះ។

25. សហចៅក្រមស៊ើបអង្កេតបានធ្វើការកត់សម្គាល់ ជាថ្មីទៀត ដោយពុំបានផ្តល់មូលដ្ឋានការពិតនិងភស្តុតាង ដើម្បីគាំទ្រដល់ការអះអាងរបស់ខ្លួនថា "ស្ថានភាពនេះគឺត្រូវបានគេដឹងថាលែងមានលក្ខណៈដូចគ្នាទៀតហើយ ដោយហេតុថាមានការចោទប្រកាន់ជាផ្លូវការត្រូវបានចាប់ផ្តើមឡើងហើយ"[21]។ ចំណុចនេះហាក់ដូចជាមិនទំនងទាល់តែសោះ។ អ្នកធ្វើអត្ថាធិប្បាយនានា និង អ្នកសារព័ត៌មានបានចោទប្រកាន់លោក **អៀង សារី** ជាយូរមកហើយថាបានពាក់ព័ន្ធនៅក្នុងបទឧក្រិដ្ឋ ដែលចោទប្រកាន់ថាបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[22]។ ទាំងជនកម្ពុជាធម្មតា និង ប្រវត្តិវិទូបរទេសនានាហាក់ដូចជាសន្មត់ថាគាត់មានពិរុទ្ធ។ ជាការពិតណាស់ វាមិនមែនជាការបំផ្លើសសំដីក្នុងការលើកឡើង នៅទីលាននៃមតិសាធារណៈជន ត្រូវបានដុតបញ្ឆេះអស់រយៈពេលជាច្រើនឆ្នាំមកហើយ ដោយសេចក្តីថ្លែងការណ៍ សេចក្តីប្រកាសព័ត៌មាន និង បណ្ឌិតសាស្ត្រាចារ្យអក្សរសាស្ត្រ ចាប់ពី "អ្នកជំនាញ" ជនជាតិកម្ពុជាផ្សេងៗ (រួមទាំងអ្នកដែលកំពុងបំរើការងារនៅ ក.ស.ព. និង ក.ស.ច.ស. ផងដែរ) ដែលជាសេចក្តីសន្និដ្ឋានបានធ្វើរួចទៅហើយថា សមាជិកជាន់ខ្ពស់ទាំងអស់របស់ខ្មែរក្រហមមានពិរុទ្ធ។ ដូច្នេះ ការលើកឡើងថា ស្ថានភាពត្រូវបានគេយល់ឃើញថាមានភាពខុសគ្នា ដោយសារតែការចោទប្រកាន់ជាផ្លូវការបានចាប់ផ្តើមឡើងនោះ គឺផ្ទុយគ្នានឹងតថភាពពិត និង សុភនិច្ឆ័យ។

26. រួមសេចក្តីមក សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយការសំអាងសេចក្តីសម្រេចរបស់ខ្លួនទៅលើវិចារណញ្ញាណអរូបី និង លើទស្សនៈយល់ឃើញជាទូទៅ ដោយមិនពឹងផ្អែកទៅលើអង្គហេតុ។ ក្នុងការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឱ្យមានកំហុសខាងអង្គហេតុ និង បានរំលោភបំពានលើបទដ្ឋានយុត្តិធម៌អន្តរជាតិ។

### *គ. គ្មានហានិភ័យពិតប្រាកដថាលោក អៀង សារី នឹងជ្រៀតជ្រែកដល់សាក្សី*

[21] ដូចខាងលើ ។

[22] សូមអាន ឧទាហរណ៍ "បេក្ខជនទាំងប្រាំពីរនាក់ដែលប្រឈមមុខនឹងការចោទប្រកាន់" និពន្ធដោយ Steve Heder ។

00159052



27. ក្នុងការយល់ឃើញថាមានហានិភ័យដែលលោក **អៀង សារី** នឹងជ្រៀតជ្រែកលើសាក្សី ប្រសិនបើមិនឃុំខ្លួនគាត់នោះទេ សហចៅក្រមស៊ើបអង្កេតបានកត់សម្គាល់ថា ៖

"មានការភ័យខ្លាចថាប្រសិនបើអនុញ្ញាតឱ្យនៅក្រៅឃុំ ជនត្រូវចោទព្យាយាម និង រៀបចំធ្វើការដាក់សម្ពាធបែបនេះ។ ម្យ៉ាងវិញទៀត **អៀង សារី** នឹងមានសិទ្ធិពិនិត្យសំណុំរឿងស៊ើបសួរទាំងមូលដែលរួមមាន ជាពិសេស កំណត់ហេតុស្តាប់ចម្លើយសាក្សី ពាក្យបណ្តឹង និង ការសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ក្រៅពីនេះ ប្រសិនបើប្រភេទអង្គហេតុធ្វើឱ្យជនសង្ស័យពិបាកក្នុងការរកអត្តសញ្ញាណ និង ជះឥទ្ធិពលលើសាក្សីសំខាន់ៗនោះ ចំណុចនេះលែងចោទជាបញ្ហាដល់ជនត្រូវចោទហើយ នៅពេលដែលជននេះដឹងអំពីអត្តសញ្ញាណរបស់សាក្សីដាក់បន្ទុក និង ជនរងគ្រោះដែលពាក់ព័ន្ធដោយនីតិវិធី។ ប្រឈមមុខនឹងស្ថានភាពថ្មីនេះ មានយុត្តិកម្មបញ្ជាក់ ជាពិសេស ដល់ការភ័យខ្លាចក្នុងការដាក់សម្ពាធលើសាក្សី និង ជនរងគ្រោះ ប្រសិនបើ ជនត្រូវចោទអាចទាក់ទង ដោយគ្មានការត្រួតពិនិត្យ ជាមួយជនទាំងនេះ ដោយហេតុថា ជននេះមានញាតិមិត្ត និង អតីតអ្នកនៅក្រោមបង្គាប់ជាច្រើន នៅក្នុងតំបន់ភ្នំម៉ាឡៃ ប៉ៃលិន ឬ ភ្នំពេញ ដែលមានខ្លះបច្ចុប្បន្ននេះស្ថិតក្នុងតំណែងដែលមានឥទ្ធិពល និង មានជនប្រដាប់អាវុធនៅជុំវិញខ្លួនផង។"

28. សេចក្តីសម្រេចឃុំខ្លួនជនត្រូវចោទដោយសារមូលហេតុថា ជននេះអាចជ្រែកជ្រែកដល់សាក្សី ***ត្រូវតែ*** អាងលើអង្គហេតុ និង ភស្តុតាងជាក់លាក់នៅចំពោះមុខជនត្រូវចោទ តុលាការមិនគួរអាងលើទស្សនៈអរូបីទាំងនោះឡើយ[23]។ លើសពីនេះទៅទៀត អង្គហេតុដែលថាជនត្រូវចោទមានអំណាច និង មានឥទ្ធិពល ***មិនមែន*** មានន័យ ជាស្វ័យប្រវត្តិថា គាត់នឹងប្រើប្រាស់វាដោយខុសច្បាប់នោះទេ[24]។

---

23 សេចក្តីសម្រេចដោះលែង Haradinaj កថាខ័ណ្ឌទី ២២ និង ៤៧ "ការវាយតំលៃថាតើជនត្រូវចោទអាចបង្កគ្រោះថ្នាក់ដែរឬទេនោះ មិនអាចសំអាងតែទៅលើចំនុចអរូបីនោះទេ។ ត្រូវបង្ហាញពីគ្រោះថ្នាក់ដែលច្បាស់លាស់។ [...] "មិនមានការបង្ហាញថា ជនត្រូវចោទអាចបង្កគ្រោះថ្នាក់ពិតប្រាកដលើជនណាម្នាក់នោះទេ រួមទាំង ជនរងគ្រោះ និង សាក្សីផង នាំឱ្យអង្គជំនុំជម្រះសាលាដំបូងមិនយល់ស្របថា ផលប៉ះពាល់អវិជ្ជមានទៅលើទស្សនៈយល់ឃើញជាសាធារណៈពីសុវត្ថិភាពរបស់សាក្សីសំខាន់ៗ គ្រប់គ្រាន់សម្រាប់ជាមូលហេតុដើម្បីបដិសេធការដោះលែងបណ្តោះ អាសន្ននោះទេ។ [...] [គ្មានភស្តុតាងណាដែលលើកឡើងថា ជនត្រូវចោទបានជ្រៀតជ្រែក ឬអាចនឹងជ្រែកដល់ ការចាត់ចែងយុត្តិធម៌នោះឡើយ"។

24 សេចក្តីសម្រេចដោះលែង Haradinaj កថាខ័ណ្ឌទី ៤៧ (ការលើកឡើងជាសំអាងរវាង រដ្ឋអាជ្ញា ទល់នឹង Prlic' និង ជនត្រូវចោទដទៃទៀត. សំណុំរឿងលេខ IT-០៤-៧៤-PT ដីកាបង្គាប់ឱ្យដោះលែងឈ្មោះ Bruno Stojic' ជាបណ្តោះអាសន្ន ចុះថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ ២០០៤ កថាខ័ណ្ឌ ២៨)។

29. ប្រសិនបើជាការពិត ការសាកល្បងដោះលែងឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន គឺថា ជនត្រូវចោទត្រូវរួចផុតពីអំណាច និង ឥទ្ធិពលឃ្លាំមើលពិតប្រាកដមែន ចុះថាតើហេតុអ្វីបានជាជនត្រូវចោទដែលមានឥទ្ធិពល និង អំណាចប្រកបទៅដោយសក្ដានុពលមួយចំនួនធំ ត្រូវបានដោះលែងឲ្យនៅក្រៅឃុំជាបណ្ដោះអាសន្ន នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មិនមែនតែក្នុងដំណាក់កាលបុរេជំនុំជម្រះប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងនៅអំឡុងពេលវិស្សមកាលរដូវត្រជាក់ និង រដូវក្ដៅក្នុងពេលសវនាការ។ ប្រការនេះអាចត្រៀមទុកឲ្យមើលឃើញជាស្រេចតាមរយៈឧទាហរណ៍លើកឡើងនៅក្នុង ឧបសម្ព័ន្ធ ក។

30. ជាចុងក្រោយ វាធ្វើឲ្យនឹកឃើញថា នៅក្នុងរយៈពេលជាងដប់ឆ្នាំ តាំងពីគាត់បានធ្វើសមាហរណកម្មជាមួយរាជរដ្ឋាភិបាលកម្ពុជាមក លោក អៀង សារី មិនដែលបានជេរប្រមាថមើលងាយ គំរាមកំហែង ឬ វាយប្រហារលើសាក្សីសក្ដានុពលណាម្ដងឡើយ ទោះបីជាគាត់បានដឹង (ដូចមនុស្សគ្រប់រូបដទៃទៀតនៅក្នុងប្រទេសកម្ពុជាបានដឹងដែរ) ថា សហគមន៍ជាតិ និង អន្តរជាតិបានចូលរួមនៅក្នុងការបង្កើតតុលាការមួយ ដែលមានគោលបំណងកាត់ទោស យ៉ាងហោចណាស់ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ដែលរងការចោទប្រកាន់នោះដែរ។

31. រួមសេចក្ដីមក សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយការសំអាងសេចក្ដីសម្រេចរបស់ខ្លួនទៅលើវិចារណញ្ញាណអរូបី និង លើទស្សនៈយល់ឃើញជាទូទៅ ដោយមិនពឹងផ្អែកទៅលើអង្គហេតុ។ ក្នុងការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យមានកំហុសខាងអង្គហេតុ និង បានរំលោភបំពានលើបទដ្ឋានយុត្តិធម៌អន្តរជាតិ។

## *ឃ. គ្មានហានិភ័យពិតប្រាកដដែលថាលោក អៀង សារី នឹងរត់គេចខ្លួន*

32. ក្នុងការយល់ឃើញថា មានហានិភ័យដែលលោក **អៀង សារី** នឹងរត់គេចខ្លួន នោះសហចៅក្រមស៊ើបអង្កេតបានលើកឡើងថា៖

> "ម្យ៉ាងវិញទៀត មានធាតុមួយចំនួនបង្ហាញថា **អៀង សារី** (ដែលមានលំនៅដ្ឋាននៅបរទេស និង ដែលធ្លាប់ធ្វើដំណើរច្រើនដងទៅក្រៅប្រទេសកម្ពុជា) មានមធ្យោបាយសម្ភារៈ ដែលអាចងាយនឹងរត់គេចខ្លួន រួមទាំងការរត់ទៅកាន់ប្រទេសផ្សេងទៀត ដូចជាប្រទេសដែលមិនមានកិច្ចព្រមព្រៀងធ្វើបត្យាប័នជាមួយប្រទេសកម្ពុជា។ **អៀង សារី** ដែលត្រូវប្រឈមនឹងទោសឧក្រិដ្ឋជាប់ឃុំឃាំងមួយជីវិត បានធ្វើការប្រកាសជាសាធារណៈច្រើនដងមកហើយថាគាត់បដិសេធមិនចូលខ្លួននៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញឡើយ។

ការប្រកាសទាំងនេះ ជាក់ច្បាស់ ធ្វើឱ្យស្រពិចស្រពិលដល់ជំហររបស់ជននេះក្នុងការបង្ហាញខ្លួនក្នុងដំណាក់កាលជំនុំជម្រះ។ ដូចនេះមានការភ័យខ្លាចថា ជននេះអាចស្វែងរកការគេចខ្លួនពីតុលាការ។"

33. ដូចមាននៅក្នុងការវាយតំលៃថាតើជនត្រូវចោទមានគ្រោះថ្នាក់ចំពោះខ្លួនឯង ឬ ដល់អ្នកដទៃ ដែរឬទេ ប្រសិនបើត្រូវបានដោះលែងបណ្តោះអាសន្ន នោះសេចក្តីសម្រេចឃុំខ្លួនជនត្រូវចោទ ដោយយោងទៅលើមូលហេតុថាអ្នកនោះអាចមានហានិភ័យរត់គេចខ្លួន *ត្រូវតែ* សំអាងលើអង្គហេតុ និង ភស្តុតាងជាក់លាក់ គឺមិនមែនយោងទៅលើទស្សនៈអរូបី ឬ ពាក្យសំដីស្មានៗនោះទេ។ ហានិភ័យរត់គេចខ្លួន *ដែលយល់ឃើញនោះ* ត្រូវកើតចេញពីអង្គហេតុយ៉ាងគ្រប់គ្រាន់។ វា *មិនអាច* ត្រូវវាយតំលៃ ហើយនិងសន្មត់ថាពិត ដោយយោងទៅលើមូលដ្ឋាននៃភាពធ្ងន់ធ្ងរនៃបទល្មើសតែប៉ុណ្ណោះទេ[25]។ សំអាងហេតុត្រូវយោងទៅលើកត្តាជាក់លាក់ ទោះជាគាំទ្រ ឬ បដិសេធនឹងភាពគ្រោះថ្នាក់នោះក៏ដោយ[26]។ ដូចដែលបានយល់ឃើញដោយតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប (The European Court of Human Rights) ដែរថា ចំណុចទាំងនេះមានរាប់បញ្ចូលតាំងពីចរិតលក្ខណៈរបស់ជនត្រូវចោទ ស្ថានភាពសុខភាព ចំណងគ្រួសារ ធនធានសម្ភារៈ និង ហិរញ្ញវត្ថុ ព្រមទាំងការជាប់ទាក់ទងដទៃទៀតទៅនឹងយុត្តាធិការ[27]។

34. កាលណាហានិភ័យរត់គេចខ្លួន គឺជាមូលហេតុស្របច្បាប់តែមួយគត់សម្រាប់ការឃុំខ្លួនបណ្តោះ នោះតុលាការគួរតែចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន រង់ចាំការជំនុំជម្រះដល់អង្គសេចក្តី ប្រសិនបើទទួលបានការធានាពីជនត្រូវចោទថា ជននេះនឹងមានវត្តមានពេលសវនាការ[28]។

---

[25] Bernard ទល់នឹង ប្រទេសបារាំង នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០០៦ កឋាខ័ណ្ឌ ៤៥ ។ Muller ទល់នឹង ប្រទេសបារាំង នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ កឋាខ័ណ្ឌ ៤២។ Tomasi ទល់នឹង ប្រទេសបារាំង នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍ អ៊ឺរ៉ុប ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៩៩២ កឋាខ័ណ្ឌ ៩៨។ Lettellier ទល់នឹង ប្រទេសបារាំង នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ១៩៩១ កឋាខ័ណ្ឌ ៤៣។ Neumeister ទល់នឹង ប្រទេស អូទ្រីស នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ១៩៦៨ កឋាខ័ណ្ឌ ១០។

[26] Yagci និង Sargin ទល់នឹង ប្រទេសទួគី នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ១៩៩៥ កឋាខ័ណ្ឌ ៥២។

[27] Neumeister ទល់នឹង ប្រទេសអូទ្រីស នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៩៦៨ កឋាខ័ណ្ឌ ៥២។

[28] Tomasi ទល់នឹង ប្រទេសបារាំង នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ២៧ ខែសីហា ឆ្នាំ ១៩៩២ កឋាខ័ណ្ឌ ៩៨។ Lettellier ទល់នឹង ប្រទេសបារាំង នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អ៊ឺរ៉ុប ចុះថ្ងៃទី ២៦

00159055



យើងខ្ញុំស្នើសុំដោយក្ដីគោរពថា ការធានាបែបនេះត្រូវតែបានគាំទ្រ និង ទទួលយក ពេលណាមានការគាំទ្រដោយការធានាបន្ថែមទៀតពីអាជ្ញាធរមានសមត្ថកិច្ចតាមផ្លូវច្បាប់ ដូចជានគរបាលមូលដ្ឋាន ដូចនៅក្នុងរឿងក្ដីនេះ ដោយមានការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា[29] ។

35. ដោយគ្រាន់តែបញ្ជាក់យ៉ាងសាមញ្ញថា លោក **អៀង សារី** ប្រហែលជាមានទ្រព្យសម្បត្តិ មានមិត្តភ័ក្ដបរទេស និង មានលិខិតឆ្លងដែន មិនមែនជាយុត្តិកម្មគ្រប់គ្រាន់ដើម្បីតម្រូវថាត្រូវតែបដិសេធការដោះលែងបណ្ដោះអាសន្ននោះទេ។ ដូចដែលបានកត់សំគាល់ខាងលើ វាមានការដឹងឮយ៉ាងទូលំទូលាយនៅពាសពេញប្រទេសកម្ពុជាថា សហគមន៍ជាតិនិងអន្តរជាតិបានចូលរួមចំណែកក្នុងការបង្កើតតុលាការមួយ ក្នុងគោលបំណងកាត់ទោស យ៉ាងហោចណាស់ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលរងការចោទប្រកាន់។ វាក៏ត្រូវបានគេដឹងឮជាទូទៅផងដែរថា **តាម៉ុក** ក៏ដូចជា **កាំង ហ្គេចអ៊ាវ** (ដែលគេស្គាល់ថា "ឌុច") បានស្ថិតនៅក្នុងការឃុំឃាំងអស់រយៈពេលជាច្រើនឆ្នាំ ខណៈពេលរង់ចាំការបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ[30]។ គ្មានអ្វីគួរឆ្ងល់ទេថាលោក **អៀង សារី** ក៏បានដឹងឮរឿងហេតុទាំងអស់នេះដែរ។ ដោយជំទាស់នឹងព្រឹត្តិការណ៍នៅពីក្រោយរឿងនេះ ប្រសិនបើការផ្ដល់ហេតុផលរបស់សហចៅក្រមស៊ើបអង្កេតត្រូវតែមានទម្ងន់គួរឲ្យជឿបាន ដូច្នេះវាអាចត្រូវបានសន្មត់ថា ភស្តុតាងដែលចង្អុលបង្ហាញខ្លះនោះ ត្រូវតែមានមែន ទោះបីបន្តិចបន្តួចក៏ដោយ ដើម្បីបង្ហាញថាលោក **អៀង សារី** បានប្រើប្រាស់ដោយខ្លួនគាត់នូវទ្រព្យសម្បត្តិ មិត្តភ័ក្ដបរទេសនិងលិខិតឆ្លងដែនដែលសន្មត់ថាគាត់មាននោះ ដើម្បីចាកចេញពីប្រទេសកម្ពុជា ឬ ដើម្បីលាក់បំពួនអាត្មា ជាពិសេសក្រោយពេលបង្កើតឡើង ដែលមានការដឹងឮជាសាធារណៈ នូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។ ការិយាល័យសហព្រះរាជអាជ្ញាពុំបានផ្ដល់ភស្តុតាងណាមួយ ហើយសហចៅក្រមស៊ើបអង្កេតក៏ពុំបានពឹងអាស្រ័យលើភស្តុតាងណាមួយឡើយ ដោយហេតុថាគ្មានភស្តុតាងបែបនោះទេ។

---

ខែមិថុនា ឆ្នាំ១៩៩១ កឋាខ័ណ្ឌ ៤៦។ *Wemhoff* ទល់នឹង ប្រទេសអាល្លឺម៉ង់ នៅចំពោះមុខតុលាការសិទ្ធិមនុស្សសហគមន៍អឺរ៉ុប ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ១៩៦៨ កឋាខ័ណ្ឌ ១៥។

29 ក្រោមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់ទោសនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ មិថុនា ឆ្នាំ ២០០៣ មាត្រា ២៤ ៖ រាជរដ្ឋាភិបាលកម្ពុជាទទួលខុសត្រូវ "ក្នុងការចាត់វិធានការសមស្រប និង មានប្រសិទ្ធិភាព ដែលចាំបាច់ដើម្បីធានានូវសន្តិសុខ សុវត្ថិភាព និង ការការពារ" ដល់ជនជាប់ចោទ។

30 ការពិតដែលថា រាជរដ្ឋាភិបាលកម្ពុជាមិនកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមដែលបានចោទប្រកាន់ទាំងពីររូបនេះ បន្ទាប់ពីការឃុំឃាំងអស់ជាច្រើនឆ្នាំ ជាពិសេស ដោយទទួលស្គាល់នូវលក្ខខណ្ឌសុខភាពដែលមិនទៀងនិងវ័យជរាភាពរបស់ **តាម៉ុក** គឺចង្អុលនូវចេតនារបស់ខ្លួនក្នុងការរង់ចាំរហូតដល់មានការបង្កើតឡើងនូវអង្គជំនុំជម្រះវិសាមញ្ញនេះ ដើម្បីកាត់ទោសបុគ្គលទាំងនេះ និង ជនជាប់ចោទដែលបានចោទប្រកាន់ដ៏សំខាន់ដទៃទៀត។

36. រួមសេចក្ដីមក សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយការសំអាងសេចក្ដីសម្រេចរបស់ខ្លួនទៅលើវិចារណញ្ញាណអរូបី និង លើទស្សនៈយល់ឃើញជាទូទៅ ដោយមិនពឹងផ្អែកទៅលើអង្គហេតុ។ ក្នុងការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឲ្យមានកំហុសខាងអង្គហេតុ និង បានរំលោភបំពានលើបទដ្ឋានយុត្តិធម៌អន្តរជាតិ។

*ង. មានលក្ខខណ្ឌត្រួតពិនិត្យមួយចំនួនដែលធានាទប់ស្កាត់ហានិភ័យ*

37. ដោយមិនរាប់បញ្ចូលការដាក់លក្ខខណ្ឌដ៏តឹងរ៉ឹងមកលើលោក **អៀង សារី** បើសិនជាត្រូវបានដោះលែងបណ្ដោះអាសន្ន ដូចជាលក្ខខណ្ឌដែលដាក់ចេញដោយតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) លក្ខខណ្ឌជាក់ស្ដែងបំផុតដែលគ្មានហានិភ័យសំរាប់ការដោះលែងបណ្ដោះអាសន្ន គឺការកែប្រែពីលក្ខខណ្ឌឃុំឃាំងបច្ចុប្បន្នឲ្យទៅជាការឃុំឃាំងក្នុងផ្ទះ ដែលជាទម្រង់មួយបែបទៀតនៃការឃុំខ្លួនប៉ុណ្ណោះ សំរាប់ចេតនានិងគោលបំណងទាំងអស់។

38. ការឃុំខ្លួនក្នុងផ្ទះត្រូវបានគេយល់ថាជាទំរង់នៃការត្រួតពិនិត្យតាមផ្លូវតុលាការ។ មាត្រា ២២៣ ដល់ ២៣០ នៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ ២០០៧) ចែងពីបទបញ្ញត្តិសំរាប់ការត្រួតពិនិត្យតាមផ្លូវតុលាការ។ អំណះអំណាងរបស់ ក.ស.ព. ដែលថា "មិនមានយុត្តិសាស្ត្រ ឥតមានការអនុវត្តជាធម្មតា ឬ អត់មានសមត្ថភាពពិតជាក់ស្ដែង ដើម្បីផ្ដល់ ទោះបី ការរក្សាសន្តិសុខ ឬ យន្តការប្រតិបត្តិក្ដី សំរាប់ជនជាប់សង្ស័យដែលអាចនឹងត្រូវដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[31]" គឺមិនទាក់ទិន និង មិនអាចជឿបានឡើយ។ ក្រៅពីអង្គហេតុដែលថា ក.ស.ព. មិនបានផ្ដល់នូវមូលដ្ឋានអ្វីចំពោះការអះអាងនេះ ប្រសិនបើទឡ្ហីករណ៍នេះត្រូវបានទទួលយក អញ្ចឹងតទៅ នឹងពុំមានជនជាប់សង្ស័យ ឬ ជនជាប់ចោទណាម្នាក់អាចទទួលបានប្រយោជន៍ពីបទបញ្ញត្តិនៃការត្រួតពិនិត្យតាមផ្លូវតុលាការឡើយ ដោយសារតែគ្មានយុត្តិសាស្ត្រក្រោយពីសវនាការ ឬ ពីការសួរដេញដោល ៖ ពាក្យប្រដៅបែបសុភាសិត **មាន់និងស៊ុត** (*Chicken and egg*) ។

39. ទោះបីជាការយល់ឃើញរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្ដីសម្រេចចុះនៅថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០០៧ របស់ខ្លួនលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់ **កាំង ហ្គេចអ៊ាវ** ហៅ "**ឌុច**"[32]ក្ដី អង្គបុរេជំនុំជម្រះគួរពិនិត្យឡើងវិញនូវជម្រើសនៃការឃុំខ្លួនផ្សេងដែលគេស្គាល់យ៉ាងទូលំ

---

[31] កំណត់ត្រា លេខ ១២ កថាខណ្ឌ ៤១។

[32] កថាខណ្ឌ ៦០។

ទូលាយថា បានជោគជ័យបំផុតក្នុងរឿងក្ដី ប៊ីលចាណាប្លាវស៊ីក ( Biljana Plavsic) នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី[33]។ ទោះបីត្រូវបានចោទពីបទទទួលខុសត្រូវខាងព្រហ្មទណ្ឌជាបុគ្គល (មាត្រា ៧(១) របស់លក្ខន្តិកៈនៃតុលាការនេះ) និង ការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ថ្នាក់លើ (មាត្រា ៧(៣) ជាមួយនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង/ឬ ការសមគំនិតប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មាត្រា ៤) ការសំលាប់បំផុតពូជ ការធ្វើមនុស្សឃាត ការធ្វើទុកបុកម្នេញដោយមូលហេតុ នយោបាយ ជាតិសាសន៍ និង សាសនា ការជម្លៀសចេញ ផ្លាស់ពីអំពើអមនុស្សធម៌ (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មាត្រា ៥) និងការធ្វើមនុស្សឃាត (ការរំលោភបំពាននៃច្បាប់ ឬ ទំនៀមទម្លាប់សង្គ្រាម មាត្រា ៣) ប៊ីលចាណា ប្លាវស៊ីក ដែលជាមន្ត្រីអាជ្ញាធរស៊ីវិលមានឋានៈខ្ពស់ម្នាក់នៃ **Republika Srbska** នៃប្រទេស បូស្នៀ និង ហែហ្សេ

---

[33] រដ្ឋអាជ្ញា តទល់នឹង Plavšić, IT-00-39 & 40/1 សេចក្ដីសំរេចលើពាក្យសុំដោះលែងបណ្ដោះអាសន្នរបស់ ប៊ីលចាណា ប្លាវស៊ីក ចុះថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០០១។ ខាងក្រោមនេះជាលក្ខខណ្ឌសំរាប់ការឃុំឃាំងក្នុងផ្ទះដែលគេប្រើប្រាស់លើ ប្លាវស៊ីក ៖

ក) ត្រូវស្ថិតក្នុងដែនកំណត់នៃទីក្រុង បែលហ្គ្រាដ។

ខ) ប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រសួងយុត្តិធម៌។

គ) រាយការណ៍រាល់ថ្ងៃទៅនគរបាលមូលដ្ឋាននៃទីក្រុង បែលហ្គ្រាដ។

ឃ) រាយការណ៍ពីអាសយដ្ឋានដែលខ្លួននឹងទៅស្នាក់នៅទៅក្រសួងយុត្តិធម៌ និង ទៅការិយាល័យរដ្ឋបាលនៃសាលាក្ដីអន្តរជាតិនេះ។

ង) យល់ព្រមឲ្យក្រសួងយុត្តិធម៌ចុះពិនិត្យមើលនៅនគរបាលមូលដ្ឋានអំពីវត្តមានរបស់ខ្លួន និង ចុះទស្សនកិច្ចជាលក្ខណៈម្ដងម្កាលនិងពុំបាច់ប្រាប់មុនចំពោះជនជាប់ចោទដោយក្រសួងយុត្តិធម៌ ឬ ដោយបុគ្គលដែលចាត់តាំងដោយការិយាល័យរដ្ឋបាលនៃសាលាក្ដីអន្តរជាតិនេះ។

ច) មិនត្រូវមានទំនាក់ទំនងជាមួយសហជនជាប់ចោទដទៃទៀតក្នុងរឿងក្ដី។

ឆ) មិនត្រូវមានទំនាក់ទំនងជាមួយមិនថាយ៉ាងម៉េចក៏ដោយ ឬ ដោយវិធីណាមួយក្ដី ដែលរំខានដល់ជនរងគ្រោះ ឬ សាក្សីសំខាន់ៗ ឬ ក៏តាមវិធីផ្សេងទៀត រំខានដោយវិធីណាមួយដល់នីតិវិធី ឬ ដល់ការគ្រប់គ្រងយុត្តិធម៌។

ជ) មិនត្រូវពិភាក្សារឿងក្ដីខ្លួនជាមួយនរណាម្នាក់ រួមទាំងសារព័តមាន លើកលែងតែមេធាវីរបស់ខ្លួន។

ឈ) បន្តសហប្រតិបត្តិការជាមួយសាលាក្ដីអន្តរជាតិនេះ។

ញ) ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនទៅតាមតម្រូវការទាំងឡាយរបស់អាជ្ញាធរនៃ សាធារណរដ្ឋ សែប៊ី ដែលចាំបាច់ដើម្បីឲ្យពួកគេបំពេញឲ្យបានសមស្របតាមកាតព្វកិច្ចរបស់គេក្នុងដីកានេះ និង ក្នុងការធានារបស់ពួកគេ។

ដ) ត្រឡប់ទៅកាន់សាលាក្ដីអន្តរជាតិនេះវិញនៅពេលវេលាណាជាក់លាក់ និង នៅកាលបរិច្ឆេទជាក់លាក់ណា តាមដែលអង្គជំនុំជម្រះនឹងកោះហៅ។ និង

ឋ) ប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនទៅតាមដីកាទាំងឡាយនៃអង្គជំនុំជម្រះ ដែលកែប្រែនូវលក្ខខណ្ឌណាមួយ ឬ បញ្ឈប់នៃការដោះលែងបណ្ដោះអាសន្ននេះ ។

ហ្គូវីណា (Bonia and Herzegovina) ត្រូវបានដោះលែងបណ្ដោះអាសន្នឱ្យឃុំឃាំងក្នុងផ្ទះនាទីក្រុងប៉ែលហ្រ្គាដ នៃប្រទេស សែប៊ី កាលពីថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ ២០០១ ទោះជានៅពេលនោះ រដ្ឋាភិបាលសែប៊ី គ្មានកិច្ចសហប្រតិបត្តិការអ្វីគួរឱ្យកត់សំគាល់ខ្លាំងជាមួយ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី នេះក៏ដោយ។ អ្នកស្រី ប្លាវស៊ីក ត្រូវស្ថិតនៅក្នុងការឃុំឃាំងក្នុងផ្ទះ សូម្បី តែខណៈពេលរង់ចាំការសម្រេចទោសក្ដី បន្ទាប់ពីគាត់បានឆ្លើយទទួលពិរុទ្ធរបស់ខ្លួនជាសាធារណៈ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងមួយជាមួយអង្គអយ្យការ ដែលតម្រូវឱ្យគាត់សហការយ៉ាងពេញលេញ ព្រមទាំងផ្ដល់នូវព័ត៌មាន ដែលមានជាប់ពាក់ព័ន្ធនឹងការដាក់ពិរុទ្ធប្រឆាំងខ្លួនឯងផង និង ប្រឆាំងនឹងអ្នកផ្សេងទៀតផង[34] ។

40. ក្នុងការលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជាមិនមានសមត្ថភាព ដើម្បីផ្ដល់សន្តិសុខដល់លោក អៀង សារី ឬ ដឹកជញ្ជូនគាត់ ដោយសុវត្ថិភាពទៅកាន់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងដំណាក់កាលនីតិវិធីស៊ើបអង្កេត ឬ ដំណាក់កាលបុរេជំនុំជម្រះនៃដំណើរការរឿងក្ដីជាទៀងពេលកំណត់ នោះ ធម្មតា គឺជាការមិនអើពើសុទ្ធសាធលើកិច្ចខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដែលធ្វើឡើងដោយរាជរដ្ឋាភិបាលកម្ពុជា និង ជាពិសេស ដោយសម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ក្នុងការនាំមកនូវសុខសន្តិភាព និង ភាពសុខសាន្តដល់ប្រទេសកម្ពុជា។

41. រួមសេចក្ដីមក សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានលើឆន្ទានុសិទ្ធិរបស់ខ្លួន ដោយការសំអាងសេចក្ដីសម្រេចរបស់ខ្លួនទៅលើវិចារណញ្ញាណអរូបី និង លើទស្សនៈយល់ឃើញជាទូទៅ ដោយមិនពឹងផ្អែកទៅលើអង្គហេតុ។ ក្នុងការធ្វើបែបនេះ សហចៅក្រមស៊ើបអង្កេតបានធ្វើឱ្យមានកំហុសខាងអង្គហេតុ និង បានរំលោភបំពានលើបទដ្ឋានយុត្តិធម៌អន្តរជាតិ។

## ច. *មានហានិភ័យពិតប្រាកដដល់អាយុជីវិតរបស់លោក អៀង សារី ក្រោមលក្ខខណ្ឌឃុំខ្លួនបច្ចុប្បន្ន*

42. ស្ថានភាពសុខភាពរបស់លោក អៀង សារី ត្រូវបានគេដឹងថាមានសភាពមិនទៀង។ គាត់ធ្លាប់ទទួលការវះកាត់បេះដូង។ ឯកសារពេទ្យដែលមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ខ[35] ចង្អុលបង្ហាញយ៉ាងគ្រប់គ្រាន់ថាគាត់កំពុងត្រូវការ មិនត្រឹមតែជំនួយផ្នែកពេទ្យដ៏សមរម្យនិងជាប្រចាំប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងត្រូវ

---

34 រដ្ឋអាជ្ញា ប្រឆាំង នឹង ប្លាវស៊ីក (*Prosecutor v. Plavšić, IT-00-39 & 40/1*) ដីកាបន្តការដោះលែងបណ្ដោះអាសន្ន ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០២។

35 បច្ចុប្បន្ននេះ កំណត់ត្រាពេទ្យ (Medical Records) កំពុងរង់ចាំការបកប្រែដោយសហចៅក្រមស៊ើបអង្កេត ហើយនឹងដាក់ពាក្យក្នុងលក្ខខណ្ឌជាសម្ងាត់។

ការឱ្យមានស្ថានភាពរស់នៅមួយសមស្របបំផុតសំរាប់សុខភាពដ៏ផុយស្រួយរបស់គាត់។ ខណៈពេលដែលការព្យាបាលតាមវេជ្ជសាស្ត្រត្រូវបានផ្តល់ជូនលោក **អៀង សារី** ក្តី ទន្ទឹមនេះ លក្ខខណ្ឌនៃការឃុំខ្លួនក៏ត្រូវស្ថិតក្រោមកំរិតមួយសមរម្យ សំរាប់មនុស្សដែលមានជម្ងឺដូចយ៉ាងលោក **អៀង សារី** ។

43. ដោយទទួលស្គាល់ថា មន្ទីរឃុំឃាំងរបស់ អ.វ.ត.ក. ស្ថិតក្រោមយុត្តាធិការរបស់រាជរដ្ឋាភិបាលកម្ពុជា[36] សហគមអន្តរជាតិដែលផ្តល់ជំនួយដល់ អ.វ.ត.ក. ហើយ ជាពិសេស អង្គការសហប្រជាជាតិដែលបានទទូចចង់ឱ្យមានការបង្កើតឡើងនូវតុលាការនេះ <u>មិនអាច</u>មិនអើពើអំពី ការពិតដែលថា ប្រសិនបើសុខភាពរបស់ជនជាប់ចោទណាម្នាក់ស្ថិតក្នុងភាពគ្រោះថ្នាក់ ដោយសារលក្ខខណ្ឌនៃការឃុំខ្លួន (ឬ ដោយសារតែការមិនអើពើនឹងការឃុំខ្លួនបណ្តោះអាសន្នដែលមានលក្ខណៈធូរស្រាលជាងនេះ) ដែលជាលទ្ធផលបណ្តាលឱ្យស្លាប់មុនអាយុកាល ឬ បង្កឱ្យមានមរណៈភាពដែលអាចបង្ការបាន នោះពួកគេត្រូវទទួលខុសត្រូវដោយស្មើៗគ្នា។ ធម្មតា វាធ្វើឱ្យនឹកឃើញដល់ភាពរីករវជាអន្តរជាតិទៅលើការស្លាប់របស់លោក **ស្លូបូដាន មីឡូសេវិក** (Slobodan Milošević) ខណៈពេលត្រូវកំពុងជាប់ឃុំឃាំងដោយអង្គភាពឃុំឃាំងអង្គការសហប្រជាជាតិ នៃ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ដោយមិនគិតពីមូលហេតុពិត ឬ ពីហេតុផលដែលបានយល់ដឹងចំពោះការស្លាប់នោះ។

44. កាលដែលនៅតែប្រកាន់ថា មិនមានហេតុផលអ្វីដែលគាត់មិនគួរត្រូវបានគេដោះលែងបណ្តោះអាសន្ន លោក **អៀង សារី** សូមធ្វើការស្នើសុំដោយក្តីគោរពថា ដោយមូលហេតុលក្ខខណ្ឌសុខភាពរបស់គាត់ ទម្រង់នៃការឃុំខ្លួនបណ្តោះអាសន្នដ៏សមរម្យមែនទែន គឺការឃុំឃាំងក្នុងផ្ទះ។

## IV. សេចក្តីសន្និដ្ឋាន និង ការស្នើរកភាពធូរស្រាល

45. តាមរូបមន្តដែលគាត់តែងដោយសហចៅក្រមស៊ើបអង្កេត ចំពោះការបដិសេធការដោះលែងបណ្តោះអាសន្នលោក **អៀង សារី** នោះគ្មាននរណាម្នាក់ ដែលស្ថិតនៅក្រោមអំណាចយុត្តាធិការនៃ អ.វ.ត.ក. នឹងទទួលបានការដោះលែងដោយមានលក្ខខណ្ឌឡើយ។ ការបកស្រាយណាមួយលើវិធានផ្ទៃក្នុងដែលមិនអនុញ្ញាតឱ្យវិធាននោះមានអានុភាពលើគោលបំណងរបស់វា នោះត្រូវតែបដិសេធចោល ដោយហេតុថា ជាក់ស្តែង វាមិនសមហេតុផល។ មានតែការបកស្រាយដែលសមហេតុផលប៉ុណ្ណោះ ដែលថា ប្រសិនបើមានភស្តុតាងរូបីសំខាន់ខ្លះ ដែលថាជនដែលត្រូវដោះលែងនឹងបង្កឱ្យមានការរំខានជាក់

[36] សូមមើល កិច្ចព្រមព្រៀង មាត្រា ១៤ និង មាត្រា ២៤។

លាក់ណាមួយនោះ ដូច្នេះទើបអាចមានមូលដ្ឋានសំរាប់ការបដិសេធការដោះលែងនេះ។ យ៉ាងណាក្តី នៅទីនេះគ្មានឯកសារណាសោះ ដែលថាសង្គមកម្ពុជា ដែលមានសណ្តាប់ធ្នាប់និងមានស្ថិរភាព មិនអាចផ្តល់លទ្ធភាពឲ្យមនុស្សចាស់ជរាដែលមានជម្ងឺ អាយុ ៨២ ឆ្នាំ ឃុំខ្លួនក្នុងផ្ទះរបស់គាត់ដើម្បីរង់ចាំសវនាការនោះទេ ដូច្នេះមូលដ្ឋានតែមួយគត់សំរាប់ឲ្យតុលាការធ្វើសេចក្តីសន្និដ្ឋាន គឺការជំនួសនូវសាលក្រមខ្លឹមសាររបស់ខ្លួនទៅលើភស្តុតាង។

46. ដោយសារហេតុផលទាំងអស់ដូចមានបញ្ជាក់ជូននៅទីនេះ មេធាវីការពារជនត្រូវចោទស្នើសុំ ដោយក្តីគោរព ដល់អង្គបុរេជំនុំជម្រះ សូមមេត្តាចាត់ទុកជាមោឃៈនូវដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ ហើយមេត្តាចេញសាលក្រមបង្គាប់ឲ្យកែប្រែលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ននេះ ឲ្យទៅជាការឃុំខ្លួនក្នុងផ្ទះវិញ ដែលស្ថិតនៅក្រោមលក្ខខណ្ឌតឹងរ៉ឹងហើយចាំបាច់ ដែលចេញដោយអង្គបុរេជំនុំជម្រះ ដោយអនុគ្រោះ។

សូមលោកចៅក្រមទទួលសារណាបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៣ ខែ មករា ឆ្នាំ ២០០៨

មេធាវី **អាង ឧត្តម** មេធាវី **ម៉ៃខល ជ. ខាណាវ៉ាស់**

សហមេធាវីការពារក្តីរបស់លោក **អៀង សារី**